# សមាគមបណ្តាញយុវជនកម្ពុជា
CAMBODIAN YOUTH NETWORK ASSOCIATION


# សេចក្តីប្រកាសព័ត៌មាន

## អំពី ការចេញផ្សាយរបាយការណ៍ស៊ើបអង្កេត និង ស្រាវជ្រាវ ស្តីពី ដំណើរឆ្ពោះទៅរកការវិនាសទាំងស្រុងនៃព្រៃសហគមន៍ភ្នំសេះ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

សមាគមបណ្តាញយុវជនកម្ពុជា CYN មានកិត្តិយសសូមជម្រាបជូនសាធារណជន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ ឱ្យបានជ្រាបថា សមាគមបានចេញផ្សាយរបាយការណ៍ស៊ើបអង្កេតនិងស្រាវជ្រាវស្តីពី ដំណើរឆ្ពោះទៅរកការវិនាសទាំងស្រុងនៃព្រៃសហគមន៍ភ្នំសេះ ក្នុងភូមិសាស្ត្រឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ដែលបានធ្វើឡើងចាប់ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០។ ការស៊ើបអង្កេតនិងស្រាវជ្រាវនេះ បានធ្វើឡើងតាមរយៈការប្រមូលទិន្នន័យមកពីការសម្ភាសន៍ប្រជាសហគមន៍ ការត្រួតពិនិត្យទីតាំងកាប់រានទន្ទ្រានដីព្រៃជាក់ស្តែង ការថតរូប ការថតវីដេអូអំពីទិដ្ឋភាពជាក់ស្តែង និងការកំណត់កូអរដោណេភូមិសាស្ត្រនៃការកាប់រានទន្ទ្រានដីព្រៃសហគមន៍។

លទ្ធផលនៃការស៊ើបអង្កេតនិងស្រាវជ្រាវនេះ បានរកឃើញថា ព្រៃសហគមន៍ភ្នំសេះបាននឹងកំពុងទទួលរងនូវការទន្ទ្រានកាន់កាប់ដីព្រៃស្ទើរតែទាំងស្រុងបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់និរន្តរភាពព្រៃសហគមន៍ និងបរិស្ថាន។ ក្នុងទំហំផ្ទៃដីព្រៃសហគមន៍ភ្នំសេះសរុប ៣,០៨១ហិកតា ត្រូវបានរកឃើញថាបាត់បង់គម្របព្រៃឈើធម្មជាតិលើផ្ទៃដីប្រមាណ ១,៣០៣ហិកតា ដែលក្រុមអ្នកប្រមូលទិន្នន័យបានប្រើប្រាស់វិធីសាស្ត្រធ្វើដំណើរព័ទ្ធជុំវិញតំបន់ព្រៃសហគមន៍ទាំងមូល និងការប៉ាន់ប្រមាណថា ទំហំដែលអាចបាត់បង់ថែមទៀតមានប្រមាណប្រហែល ៤៦០.៨ហិកតា។ គម្របព្រៃឈើសហគមន៍នេះភាគច្រើនត្រូវទទួលរងនូវការរានទន្ទ្រានកាន់កាប់ និងបំប្លែងទៅជាដីចម្ការរួចរាល់ ដោយត្រូវបានជំនួសមកវិញដោយដំណាំស្វាយចន្ទី ដំឡូងមី និងដំណាំឈើដាំមួយចំនួនទៀត។ របាយការណ៍នេះក៏ បានរកឃើញមានលំនៅដ្ឋានខុសច្បាប់ដែលបានសាងសង់លើដីដែលបានកាប់រានទន្ទ្រាន នៅលើដីព្រៃសហគមន៍ភ្នំសេះចន្លោះពី ៨០ ទៅ៨៥ខ្នង ដែលភាគច្រើនបានសង់ខ្ទមក្នុងទម្រង់ជារោងចាំចម្ការ និងផ្ទះបណ្តោះអាសន្ន

នៅលើក្បាលដីរបស់ខ្លួន (ពួកគេធ្វើការគ្រប់គ្រងក្បាលដីយ៉ាងតិចចន្លោះពី៥ ទៅ១០ហិកតា) ដោយភាគច្រើនមិនមានមនុស្សរស់នៅអចិន្ត្រៃយ៍ឡើយ។

ការកាប់រានទន្ទ្រានកាន់កាប់ បានគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចព្នង ដែលធ្លាប់បានដកហូតអនុផលព្រៃឈើ ដែលធ្លាប់បម្រើដល់ជីវភាពរបស់ពួកគេយ៉ាងសកម្មក្នុងរយៈពេលច្រើនទសវត្សរ៍មកហើយ។ ក្រៅពីនេះចំណុចគួរឱ្យកត់សម្គាល់មួយទៀតនោះគឺការប្រឈមនឹងការបាត់បង់ទីកន្លែងជំនឿរបស់ជនជាតិដើមភាគតិចព្នង ដែលហៅថា "ទីជំនឿភ្នំសេះ"។

ជាមួយគ្នានេះ លំហូរចូលនៃប្រជាពលរដ្ឋចំណូលស្រុក ដែលបានចូលមកទិញ និងការរានទន្ទ្រានដីព្រៃកាន់កាប់ជាកម្មសិទ្ធិ សម្រាប់ដាំដំណាំកសិឧស្សាហកម្ម ក៏មានអ្នកភូមិដែលរស់នៅជិតនោះខ្លះ ដែលមិនមានដីចម្ការ ឬមានដីចម្ការតិចតួចបានចាប់ផ្តើមកាប់រានទន្ទ្រានដីព្រៃ ដើម្បីពង្រីកដីចម្ការរបស់ខ្លួនកាន់កាប់ដីជាកម្មសិទ្ធិដោយខុសច្បាប់ ក្នុងបំណងដាំដំណាំផ្សេងៗដូចជា ស្វាយចន្ទី និងដំឡូងមីជាដើម។

របាយការណ៍ក៏បានរកឃើញថា ការរានទន្ទ្រានដីព្រៃនៅក្នុងព្រៃសហគមន៍ភ្នំសេះគឺជាសកម្មភាពខុសច្បាប់ ដែលបានចែងក្នុងច្បាប់ស្តីពីភូមិបាល និង ច្បាប់ស្តីពីព្រៃឈើ។ ចំពោះការអនុវត្តច្បាប់ និងការបំពេញមុខងាររបស់អាជ្ញាធរពាក់ព័ន្ធ មន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើ និងមន្ត្រីរដ្ឋបាលឃុំនៅមានកម្រិតនៅឡើយ ដែលជាហេតុធ្វើឱ្យព្រៃសហគមន៍ភ្នំសេះ បន្តទទួលរងនូវការកាប់រានទន្ទ្រានដីព្រៃយ៉ាងគំហុក ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់និរន្តរភាពបរិស្ថាន និងគម្របព្រៃឈើ។

រដ្ឋបាលខេត្តក្រចេះធ្លាប់បានចេញលិខិតចំនួនពីរផងដែរចំពោះករណីនេះ រួមមានសេចក្តីជូនដំណឹងលេខ០១៦/១៩ ស.ជ.ណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ស្តីពី ការបញ្ឈប់ការចូលទន្ទ្រានកាន់កាប់ដីព្រៃសហគមន៍ភ្នំសេះ និងសេចក្តីជូនដំណឹងលេខ០៤២/១៩ ស.ជ.ណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ស្តីពី ការបញ្ឈប់ការចូលទន្ទ្រាន កាន់កាប់ដីព្រៃសហគមន៍ភ្នំសេះ ព្រមទាំងមានសេចក្តីជូនដំណឹងលេខ ០០៦/២០ ស.ជ.ណ.សម របស់សាលាស្រុក សំបូរ បន្ថែមទៀត ក៏សកម្មភាពកាប់ទន្ទ្រានយកដីព្រៃសហគមន៍នៅតែបន្តកើតឡើងជាស្ទើតែជារៀងរាល់ថ្ងៃ។ បើទោះបីជាសេចក្តីជូនដំណឹងនេះមានព្រមានធ្ងន់ធ្ងរ តែសកម្មភាពនៃការកាប់រានទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់នៅតែបន្តកើតមានរហូតមកដល់បច្ចុប្បន្ន និងមានសភាពកាន់តែធ្ងន់ធ្ងរទៅៗ ដែលអាចធ្វើឱ្យព្រៃសហគមន៍ភ្នំសេះ អាចនឹងបាត់បង់ទាំងស្រុងនៅពេលអនាគត។

ផ្ទះលេខ៣៥ ផ្លូវលេខ១០១៣ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ ០៩៣ ៩១៣ ០១១ អ៊ីម៉ែល info@cyncambodia.org

ដោយមើលឃើញពីសកម្មភាពទន្ទ្រានយកដីព្រៃសហគមន៍ នៅតែបន្តកើតមានឡើងជាបន្តបន្ទាប់ ដែលគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់អនាគតព្រៃសហគមន៍ភ្នំសេះ ដែលមាននាទីយ៉ាងសំខាន់ក្នុងការរក្សាប្រព័ន្ធអេកូឡូស៊ី និងផ្តល់សារៈសំខាន់ចំពោះជីវភាពរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលរស់នៅជុំវិញតំបន់ព្រៃសហគមន៍ក្នុងការដេកហូតអនុផលព្រៃឈើ តាមរយៈរបាយការណ៍ស៊ើបអង្កេត និងស្រាវជ្រាវនេះ ក៏បានផ្តល់នូវអនុសាសន៍មួយចំនួន ដែលអាចព័ត៌មាន និងភស្តុតាងបន្ថែមទៀតដល់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងមូលដ្ឋាន រដ្ឋបាលព្រៃឈើ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលាក្នុងការបង្ការ និងបង្ក្រាបរាល់សកម្មភាពទាំងឡាយណាដែលធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ព្រៃសហគមន៍ភ្នំសេះ ដើម្បីជាប្រយោជន៍រួមសម្រាប់ប្រជាសហគមន៍នៅមូលដ្ឋានផ្ទាល់និងយើងទាំងអស់គ្នា។

**ទំនាក់ទំនងសម្រាប់ព័ត៌មានបន្ថែម៖**


- លោក **ហេង គឹមហុង** ប្រធានកម្មវិធីផ្នែកស្រាវជ្រាវ និងតស៊ូមតិ 0967 888 368
- លោក **អ៊ុត ឡាទីន** មន្ត្រីចងក្រងសហគមន៍ 016 224 426
- លោក **ហ៊ា សំអឿន** អនុប្រធានសហគមន៍ព្រៃឈើភ្នំសេះ 0719 609 653
- លោក **ហ៊ា រឿន** សមាជិកគណៈកម្មការសហគមន៍ព្រៃឈើភ្នំសេះ 0882 257 886